# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងធម្មការ និង សាសនា

លេខ ០១៤៣ ធ.ធ.សស **សេចក្តីសំរេច**

ស្តីពីការអនុញ្ញាតឲ្យ ចំឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មីដែលស្ថិតនៅ "វត្តក្តីកណ្តាល" នៃគណៈមហានិកាយ ភូមិសាម៉ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង

### រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ស្វាយរៀង លេខ ១៨១ចប ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០២.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង លេខ ៣៩មធក.ស្វរ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០២.

-យោងតាមចំណាររបស់អភិបាលស្រុកកំពង់រោទិ៍ លេខ ៧៦ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២.

-តាមសំណើសុំកសាងវត្ត របស់ចៅអធិការ និងអាចារ្យ គណៈកម្មការ វត្ត ក្តីកណ្តាល ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០២.

### សំរេច

**ប្រការ១:** អនុញ្ញាតឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មី "វត្តក្តីកណ្តាល" នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុងភូមិសាម៉ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដោយរក្សានូវក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការ២ :** ព្រះវិហារថ្មី នេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបាន ល្អប្រសើរ និងរីកចំរើន ។

**ប្រការ៣ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ជា សាវឿន

**ចម្លងជូន :**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
"ដើម្បីថ្វាយ-ជូនជ្រាប"
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-សាលាខេត្តស្វាយរៀង
-អភិបាលស្រុកកំពង់រោទិ៍
-ដូចប្រការ៣
"ដើម្បីចាត់ការអនុវត្ត"